ការពង្រឹងសមត្ថភាព

ការផ្សាយលើកទីមួយ

# កម្រងពត៌មានរបស់ចៃការ (JICA) ប្រចាំ អគ្គនាយកដ្ឋានពន្ធដារ (អពដ)

មករា ២០១៣

## មាតិកា


សមាជិកនៃគម្រោងបច្ចុប្បន្នរបស់អពដ ២

ផែនការប្រចាំឆ្នាំ ពីខែកញ្ញា២០១២ ដល់ សីហា ២០១៣ ២

សកម្មភាពសំខាន់ៗរបស់គម្រោងកន្លងមក ៣

សកម្មភាពកាលពីខែមុន ៤

ផែនការសកម្មភាពសំរាប់ខែមករា ដល់កុម្ភៈ ឆ្នាំ២០១៣ ៥

ពតិមានសំខាន់ៗ ៦


## ព្រឹត្តិការណ៍សំខាន់ៗ

- ការស្វែងយល់ពីគម្រោង
- លោក អូតាកិ អតីតអភិបាលទីភ្នាក់ងារពន្ធដារជាតិប្រទេសជប៉ុនបានធ្វើបេសកកម្មពិគ្រោះយោបល់នៅអពដ និង ខេត្តសៀមរាប ព្រមទាំងបានផ្តល់បទបង្ហាញជាសាធារណៈ នៅសាលាជាតិពន្ធដារ
- ការចាប់ទទួលពាក្យសុំអាហារូបករណ៍ក្រោមកិច្ចសហការរវាងប្រទេសជប៉ុន និង ធនាគារពិភពលោកសំរាប់មន្ត្រីពន្ធដារ

## វន្ទនាការ

យើងមានក្តីត្រេកអរជាពន្លឹកដែលបានចេញលិខិតសារពតិមានជាលើកទីមួយ ជូនចំពោះមន្ត្រីពន្ធដារកំពុងបំរើការងារនៅអគ្គនាយកដ្ឋានពន្ធដារ (អពដ)។ តាមរយៈលិខិតពតិមាននេះ យើងសូមសំណូមពរដល់អ្នកអានទាំងអស់ឲស្វែងយល់ និងចូលរួមជាមួយគម្រោងរបស់យើងអោយបានច្រើនកុះករ ដើម្បីសំរេចបាននូវគោលបំណងរបស់គម្រោងនេះ។ ដូច្នេះយើងអាចចែករំលែកពតិមានបន្តបន្ទាប់ ដើម្បីឲគម្រោងនេះមានតម្លាភាព និងភាពជោគជ័យប្រកបដោយការទទួលខុសត្រូវខ្ពស់។ ជាកិច្ចបញ្ចប់ យើងបានបរិយាយអំពីសកម្មភាពដែលបានធ្វើកន្លងមក និងពេលអនាគត។ សូមស្វែងយល់ពីគម្រោងនេះ ហើយបន្តការភ្ជាប់ទំនាក់ទំនងជាមួយយើង។

### តើយើងជានរណា

**អ្នកស្រី អ៊ិម៉ៃ តាកាកុ**



ប្រធានផ្តល់ប្រឹក្សា ដែលបានចូលកាន់តំណែងកាលពីខែឧសភា ឆ្នាំ២០១២។ អ្នកស្រីធ្លាប់បានបំរើការងារឲទីភ្នាក់ងារពន្ធដារជាតិ (ទពជ) ប្រទេសជប៉ុន ជាង២០ឆ្នាំ។ ការងារចំបងរបស់លោកស្រី គឺជាសវនករពន្ធដារ និងជំនួយការសាស្រ្តាចារ្យសម្រាប់ប្រទេសកម្ពុជា និងវៀតណាមនៅឯសាលាពន្ធដារជាតិប្រទេសជប៉ុន (សជព)។

**លោក អូអ៊ីកាវ៉ា ម៉ាសាណូរី**



អ្នកសម្របសម្រួលគម្រោងដែលបានចូលកាន់តំណែងកាលពីខែកញ្ញាឆ្នាំ២០១១។ លោកមានបទពិសោធន៍ជាមួយចៃការ (JICA) ជាច្រើនគម្រោងតាំងពីឆ្នាំ ១៩៩១។

**លោក អូន សីហា**



មន្ត្រីគម្រោង ដែលមានបទពិសោធន៍យូរឆ្នាំក្នុងគម្រោងរបស់ចៃការ (JICA) ជាមួយអពដតាំងពីជំហ៊ានទី២មកម្ល៉េះ។

**លោក វង់ ច័ន្ទរតនៈ**



មន្ត្រីគម្រោង ដែលបានចូលបំរើការងារកាលពីចុងឆ្នាំ២០១២។

## ការស្វែងយល់ពីគម្រោង

កិច្ចព្រមព្រៀងរបស់ "គម្រោងអភិវឌ្ឍន៍សមត្ថភាពសម្រាប់អពដ ក្រោមកំណែទម្រង់បណ្តាញការ ងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" (គម្រោងជំហ៊ានទី៣របស់ចៃការ) ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១១ រវាង អពដ និង ចៃការប្រចាំការនៅកម្ពុជា។ គម្រោងនេះមានរយៈពេល៣ឆ្នាំចាប់ផ្តើមកាលពីខែកញ្ញា ឆ្នាំ២០១២ ក្នុងគោលបំណងបង្កើនចំណូលពន្ធតាមរយៈការពង្រឹងរបបស្វ័យប្រកាស។ ដើម្បីសំរេចគោលបំណងនេះ យើងត្រូវពង្រឹងលើវិស័យពីរសំខាន់ៗ ដូចជា សវនកម្មពន្ធ និង សេវាអ្នកជាប់ពន្ធ។

## សមាជិកគម្រោងបច្ចុប្បន្នរបស់អពដ

សមាជិកគម្រោងបច្ចុប្បន្នត្រូវបានទទួលស្គាល់ដោយឯកឧត្តមអគ្គនាយកនៅខែកញ្ញា ឆ្នាំ ២០១២។ មន្ត្រីសរុប៥៥រូបត្រូវបានតែងតាំងពីអដព និងសាខាពន្ធដាររួមមានដូចខាងក្រោម៖

- ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារជាអគ្គនាយកគម្រោង
- ឯកឧត្តម គឹម សុភ័ក្រ្ត អគ្គនាយករង ជានាយកគម្រោង
- ឯកឧត្តម យស់ ស៊ីម៉ារ៉ាត់ អគ្គនាយករង ជានាយកគម្រោង
- លោក ហ៊ឹម ប៊ុនធឿន ប្រធាននាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជាប្រធានសម្របសម្រួលគម្រោង
- លោក ចែម វាសនា ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ ជាប្រធានក្រុមការងារផ្នែកសេវាអ្នកជាប់ពន្ធ
- លោក ហ៊ាន គ្រេង ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស ជាប្រធានក្រុមការងារសវនកម្មពន្ធ

សមាជិកក្រុមការងារនីមួយៗកំពុងធ្វើការងារលើផ្នែកបង្កើតឯកសារជំនួយស្មារតីដើម្បីធានាចបានវឌ្ឍនភាពរយៈពេលវែងរបស់អដព

## ផែនការប្រចាំឆ្នាំពីខែកញ្ញា២០១២ ដល់ សីហា២០១៣



## សកម្មភាពសំខាន់ៗរបស់គម្រោងកន្លងមក

### កញ្ញា ២០១១ ដល់ មិនា ២០១២

កុម្ភៈ៖ បានផ្តល់ "វគ្គបណ្តុះបណ្តាលនៅប្រទេសទី៣ ក្នុងប្រទេសម៉ាឡេស៊ី" (មានវត្តមានមន្ត្រីចំនួន១៦រូប)។

មិនា៖ បានផ្តល់ "វគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន" (មានវត្តមានមន្ត្រីចំនួន៧រូប)។

មិនា៖ បានធ្វើ "ការសិក្សាស្រាវជ្រាវស្តីពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធនៅប្រទេសកម្ពុជា" (ចុះផ្សាយខែកក្កដា ឆ្នាំ២០១២)។

### មេសា ២០១២ ដល់ សីហា ២០១២

មិថុនា៖ ក្រុមការងាររបស់ចៃការ (JICA) បានធ្វើទស្សនៈកិច្ចទៅសាខាពន្ធដារខណ្ឌទាំង៧ ក្នុងរាជធានីភ្នំពេញ សាខាពន្ធដារខេត្តកណ្តាល និង ខេត្តកំពង់ចាមដើម្បីស្វែងយល់ពីដំណើរការ និងបញ្ហាប្រឈមរបស់សាខានីមួយៗ។

សីហា៖ បានរៀបចំគណៈកម្មការសម្របសម្រួលគម្រោងលើកទី១ ក្រោមវត្តមានរបស់ឯកឧត្តម ស៊ឹម អៀង អតីតជាអគ្គនាយកគម្រោង និង ឯកឧត្តម យស់ ស៊ីម៉ារ៉ាត់ នាយកគម្រោង ព្រមទាំងមន្ត្រីតំណាងជាន់ខ្ពស់របស់ចៃការ និងមន្ត្រីតំណាងពីទីភ្នាក់ងារពន្ធដារជាតិ ប្រទេសជប៉ុន(ទពជ)។ ក្នុងកិច្ចប្រជុំនេះ ប្រធានផ្តល់ប្រឹក្សាបានធ្វើបទបង្ហាញពីបញ្ហាប្រឈមដែលគម្រោងបានជួបប្រទះ និងសំណើរផែនការឆ្នាំបន្ទាប់ពីខែកញ្ញា ឆ្នាំ២០១២ ដល់ ខែសីហា ឆ្នាំ២០១៣។



កិច្ចប្រជុំគណៈកម្មការសម្របសម្រួលសម្រួលគម្រោងលើកទី១
នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២

សីហា៖ បានចូលរួមសិក្ខាសាលាស្តីពីសេវាអ្នកជាប់ពន្ធ រៀបចំដោយសាខាពន្ធដារខណ្ឌដូនពេញ និងសិក្ខាសាលាស្តីពីការផ្សព្វផ្សាយពន្ធលើអចលនទ្រព្យ រៀបចំដោយសាខាពន្ធដារខណ្ឌទួលគោកដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋទូទៅក្នុងសាលាខណ្ឌទួលគោក។

សីហា៖ បានចូលរួមសហការរៀបចំសិក្ខាសាលាស្តីពីសេវាអ្នកជាប់ពន្ធជាមួយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (របាយការណ៍វាយតំលៃត្រូវបានចាត់ចែង ដោយគម្រោងដើម្បីវឌ្ឍនភាពនៅថ្ងៃ អនាគត និងសម្រាបជាឯកសារយោងដល់សាខាពន្ធដារដ៏ទៃទៀត)។

### កញ្ញា ដល់ វិច្ឆិកា ២០១២

កញ្ញា៖ ប្រធានតំណាងចៃការ (JICA) បានធ្វើជំនួបទស្សនៈកិច្ចផ្លូវការជាមួយឯកឧត្តម គង់ វិបុល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ។

កញ្ញា៖ បានដាក់របាយការណ៍ពង្រាងស្តីពី "ការវិភាគរដ្ឋបាលសារពើពន្ធ នៅប្រទេសកម្ពុជា និងផែនការសកម្មភាព" ទៅអពដ។

តុលា៖ បានផ្តល់វគ្គបណ្តុះបណ្តាលនៅប្រទេសទី៣ ក្នុងប្រទេសឥណ្ឌូនេស៊ី" (មានវត្តមានមន្ត្រីចំនួន១៨រូប)

តុលា៖ កិច្ចប្រជុំថ្នាក់នាយកគម្រោងលើកទី១បានបង្កើតឡើងដើម្បីពិភាក្សាពីផែនការសកម្មភាព

វិច្ឆិកា៖ ផែនការសកម្មភាពសំរាប់ខែកញ្ញា ឆ្នាំ២០១២ ដល់ ខែសីហា ឆ្នាំ២០១៣ ត្រូវបានអនុម័ត។

វិច្ឆិកា៖ កម្មវិធីបណ្តុះបណ្តាលតាមតំបន់ត្រូវបានធ្វើឡើងនៅសាខាពន្ធដារខណ្ឌដូនពេញ (របាយការណ៍វាយតំលៃត្រូវបានចាត់ចែងដោយគម្រោង)។

វិច្ឆិកា៖ បន្តកិច្ចពិភាក្សាក្រោមកិច្ចផ្តួចផ្តើមដោយនាយកដ្ឋានសវនកម្ម

សបហ គ្រាសដែលជាផ្នែកមួយនៃសកម្មភាពអភិវឌ្ឍន៍សម្ថតភាព។

គម្រោងនេះមានរយៈពេល១ឆ្នាំ ក្រោមកិច្ចខំប្រឹងប្រែងប្រកបដោយភាពជោគជ័យរបស់គណៈកម្មការសម្របសម្រួលគម្រោង



កិច្ចពិភាក្សាក្រោមវត្តមានរបស់ឯកឧត្តមអគ្គនាយក



## សកម្មភាពកាលពីខែមុន

ខែធ្នូ ឆ្នាំ២០១២

| អ | ច | អ | ព | ព្រ | សុ | ស |
|---|---|---|---|---|---|---|
| | | | | | | ១ |
| ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ |
| | | បាត់ដំបង | | | អ.ព | |
| ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ |
| | | បេសកកម្មរបស់លោកអូតាកិ | | | | |
| ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ |
| លោកអូតាកិ | | | អ.ព | | | |
| ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ |
| | | | | ស.ព | ស.ព | |
| ៣០ | ៣១ | | | | | |

◆អ.ព: កិច្ចប្រជុំអនុក្រុមស្តីពីការអប់រំអំពីពន្ធដារ
◆ស.ព: សិក្ខាសាលាស្តីពីសេវាអ្នកជាប់ពន្ធ

☆ របាយការណ៍ស្តីពីវគ្គបណ្តុះបណ្តាល ដែលបានចុះផ្សាយថ្ងៃទី ២០ ខែធ្នូ





ការប្រឹក្សាយោបល់ស្តីពីពត៌មានវិទ្យា

## វគ្គបណ្តុះបណ្តាលតាមតំបន់នៅបាត់ដំបង

មន្ត្រីសរុបចំនួន៧៥រូប មកពីសាខាពន្ធដារបាត់ដំបង ប៉ៃលិន និងពោធិ៍សាត់។



មូលដ្ឋានគ្រឹះគណនេយ្យសំរាប់អ្នកបណ្តុះបណ្តាល

<u>មាតិកា</u>

១. សេវាអ្នកជាប់ពន្ធ (៣ម៉ោង) ដោយ លោក ចែម វាសនា ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ និង ជាប្រធានក្រុមការងារផ្នែកសេវាអ្នកជាប់ពន្ធ

២. ការអប់រំអំពីពន្ធដារ (១.៥ម៉ោង) ដោយ អ្នកស្រី អ៊ិម៉ៃ តាកាកុ

៣. មូលដ្ឋានគ្រឹះគណនេយ្យសំរាប់អ្នកបណ្តុះបណ្តាល (៤ម៉ោង) ដោយ កញ្ញា ពេជ្រ បុប្ផាលក្ខណ៍ មន្ត្រីនាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ

៤. សវនកម្មពន្ធដារក្នុងប្រទេសជប៉ុន (១.៥ ម៉ោង) ដោយ អ្នកស្រី អ៊ិម៉ៃ តាកាកុ

៥. ការប្រឹក្សាយោបល់ស្តីពីពត៌មានវិទ្យា (១០ម៉ោង) ដោយ លោក នួន មុនីរ័ត្ន អនុប្រធានការិយាល័យ និង លោក ឃុល ចាន់រតនា អនុប្រធានការិយាល័យពត៌មានវិទ្យា



បេសកកម្មរបស់លោកអូតាកិបានធ្វើឡើងជាកិច្ចចាប់ផ្តើមសិក្ខាសាលាក្នុងគម្រោងឆ្នាំនេះ។ លោកបានលើកទឹកចិត្តឲមន្ត្រីពន្ធដារទាំងអស់ធ្វើជាវីរបុរសសំរាប់ប្រទេសជាតិ។

## បេសកកម្មរបស់លោកអូតាកិ

លោក អូតាកិ អតីតអភិបាលទីភ្នាក់ងារពន្ធដារជាតិប្រទេសជប៉ុន បានធ្វើទស្សនៈកិច្ចនៅអពដ និងសាខាពន្ធដារខេត្តសៀមរាប ក្នុងគោលបំណងផ្តល់ប្រឹក្សាយោបល់ស្តីពីសារៈសំខាន់រដ្ឋបាលសារពើពន្ធ។ លោកបានលើកទឹកចិត្តឲមន្ត្រីពន្ធដារទាំងអស់ធ្វើជាវីរបុរសតាមរយៈកាតព្វកិច្ចដ៏សំខាន់របស់ពួកគេក្នុងការប្រមូលចំណូលពន្ធសំរាប់ប្រទេសជាតិ។ លោកបានពន្យល់ពីរបៀបផ្លាស់ប្តូរបន្តិចម្តងៗពីរបបមៅការ ទៅជារបបស្វ័យប្រកាសនៅប្រទេសជប៉ុន តាមរយៈការស្វែងយល់នូវបញ្ហាប្រឈមផ្សេងៗក្នុងអតីតកាល ដោយកាត់បន្ថយអំពើពុករលួយ និងបង្កើតរង្វាន់លើកទឹកចិត្តទៅដល់មន្ត្រីពន្ធដារ ព្រមទាំងប្រកាសពីឈ្មោះអ្នកជាប់ពន្ធដែលបានប្រព្រឹត្តបទល្មើសជាលក្ខណៈសាធារណៈ ហើយផ្តល់រង្វាន់លើកទឹកចិត្តចំពោះអ្នកជាប់ពន្ធណាដែលបានប្រកាសពន្ធបានត្រឹមត្រូវ។ លោកបាននិយាយថា ការផ្តល់រង្វាន់លើកទឹកចិត្តនឹងមានប្រសិទ្ធិភាពសំរាប់រដ្ឋបាលសារពើពន្ធ។



បេសកកម្មរបស់លោកអូតាកិនៅអពដ

## បេសកកម្មរបស់លោកអូតាកិ និងសិក្ខាសាលា

ទាក់ទងទៅនឹងពត៌មានធនាគារ កាលពីខែកញ្ញា ឆ្នាំ២០១១ បទដ្ឋានរបស់ពិភពលោកទាំងមូលគឺកំពុងត្រូវបានផ្លាស់ប្តូរ ដើម្បីធានានូវសុវត្ថិភាពដោយគ្រប់គ្រងឲបាននូវមូលធនខុសច្បាប់ ដែលទំនងជាប្រភពនៃការគេចវេសពន្ធ។ ដូច្នេះ ប្រទេសកម្ពុជាគួរតែទទួលបានពត៌មានតាមរយៈហេតុផលនេះ។ លើសពីនេះទៅទៀត លោកបានឆ្លើយតបសំនួរមួយពាក់ពន្ធ័នឹងពត៌មានវិទ្យា និងបានផ្តល់យោបល់ដល់អពដថា ប្រតិបត្តិការផ្នែកពត៌មានវិទ្យាតាមប្រភេទពន្ធ និង ប្រភេអ្នកពន្ធ គឺជាផ្នែកអាទិភាពសំខាន់មួយ ជាជាងការផ្តល់សេវាអ្នកជាប់ពន្ធតាមប្រព័ន្ធពត័មានវិទ្យា។ លោកក៏បានធ្វើជំនួបពិភាក្សាជាមួយឯកឧត្តម គាត ឈុន ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

លោក អូតាកិ បានផ្តល់បទបង្ហាញក្នុងសិក្ខាសាលាស្តីពី "ប្រទេសជប៉ុនដ៏អស្ចារ្យ! គន្លឹះឈានទៅរកការរីកចំរើននៃវិស័យសេដ្ឋកិច្ច និង តួនាទីរបស់ពន្ធដារ" នៅសាលាជាតិពន្ធដារ កាលពីថ្ងៃទី ១៤ ទៅកាន់និស្សិត អ្នកជាប់ពន្ធ និង មន្ត្រីពន្ធដារ ជាង ២៥០នាក់ (មានការថតចំលងវីដេអូ)។







សិក្ខាសាលានៅសាលាជាតិពន្ធដារ

## សិក្ខាសាលាសំរាប់អ្នកជាប់ពន្ធ

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បានរៀបចំសិក្ខាសាលាស្តីពី " ការផ្សព្វផ្សាយប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជា" សំរាប់សមាគមកាត់ដេរនៅកម្ពុជា។ ឯកឧត្តមអគ្គនាយកបានបើកអង្គពិធី និងបានប្រកាសពីគោលការណ៍ថ្មីនៃការផ្តល់ពាក្យសុំបង់ពន្ធដោយមិនគិតថ្លៃទៅកាន់អ្នកបង់ពន្ធទាំងអស់ចាប់ពីដើមឆ្នាំ ២០១៣នេះតទៅ។

សាខាពន្ធដារខណ្ឌឬស្សីកែវបានរៀបចំសិក្ខាសាលាកាលពីព្រឹក ថ្ងៃទី២៨ ដល់អ្នកជាប់ពន្ធប្រមាណ៥០នាក់។ ពួកគេក៏បានទទួលនូវច្បាប់ចំលងស្តីពី "កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ" ផងដែរ។

យោងតាមការវង្វាយតំលៃរបស់សិក្ខាកាម និងការអង្កេតពីអ្នកជំនាញចៃការ (JICA) អ្នកជាប់ពន្ធធំមានចំណេះដឹងជ្រៅជ្រះជាងអ្នកជាប់ពន្ធតូច និងមធ្យម។ ក្រុមទាំងអស់បានស្នើសុំឲមានការធ្វើបទបង្ហាញតែមួយប្រធានបទ ហើយពន្យល់ឲបានស៊ីជម្រៅ ជាមួយនឹងការគណនាលេខ ព្រមទាំងឧទាហរណ៍ក្នុងសិក្ខាសាលានីមួយៗ។

"គន្លឹះឈានទៅរកភាពជោគជ័យនៃវិស័យសេដ្ឋកិច្ច" គឺអាស្រ័យលើសហគ្រាសធុនតូច និងមធ្យម ដែលបន្តធ្វើ និងពង្រីកអាជីវកម្មរបស់ខ្លួនដោយស្គាល់ពីឱកាសចំណេញ និងការធ្វើជំនួញមិនឈប់ឈរតាមរយៈលទ្ធផលនៃការចុះបញ្ជីគណនេយ្យឲបានត្រឹមត្រូវ។

(លោក អូតាកិ)

## ផែនការសកម្មភាពសំរាប់ខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០១៣

៨ ដល់ ១១ មករា៖ វគ្គបណ្តុះបណ្តាលក្នុងប្រទេសកម្ពុជា ស្តីពី "ការត្រិះរិះពិចារណា៖ ការត្រួតពិនិត្យលើរដ្ឋបាលសារពើពន្ធ"។ សាស្ត្រាចារ្យពីររូបមកពីប្រទេសជប៉ុន ដែលអ្នកជំនាញទាំងពីរត្រូវបានទទួលស្គាល់ជា គណនេយ្យករផ្នែកពន្ធដារសាធារណៈ និង ជាសហការីសាស្ត្រាចារ្យសាកលវិទ្យាល័យបានធ្វើបទបង្ហាញ និងដឹកនាំកិច្ចពិភាក្សាក្នុងទីក្រុងភ្នំពេញ។

១៧ ដល់ ១៨ មករា៖ វគ្គបណ្តុះបណ្តាលតាមតំបន់នៅសាខាពន្ធដារខេត្តស្វាយរៀង។ មន្ត្រីមកពីខេត្តព្រៃវែងក៏ត្រូវបានអញ្ជើញឲចូលរួមផងដែរ។

១៣ ដល់ ១៤ កុម្ភៈ៖ វគ្គបណ្តុះបណ្តាលតាមតំបន់នៅសាខាពន្ធដារខេត្តបន្ទាយមានជ័យ។ មន្ត្រីមកពីខេត្តឧត្តរមានជ័យក៏ត្រូវបានអញ្ជើញឲចូលរួមផងដែរ។

២៧ កុម្ភៈ ដល់ ១ មិនា៖ សិក្ខាសាលាស្តីពី "សេវាអ្នកជាប់ពន្ធ ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ" នៅអគ្គនាយកដ្ឋានពន្ធដារ។ សមាជិកក្រុមការងារនឹងអញ្ជើញចូលរួម។



សិក្ខាសាលាស្តីពីសេវាអ្នកជាប់ពន្ធ
នៅសាខាពន្ធដារខណ្ឌឬស្សីកែវ

គេហទំព័ររបស់ចៃការ (JICA)
http://www.jica.go.jp/english/index.html

## គម្រោងចៃការ (JICA) នៅអជព


អគ្គនាយកដ្ឋានពន្ធដារ
(បន្ទប់ ៦០១)
ភ្នំពេញ
ទូរស័ព្ទ 023 689 1617
ទូរសារ 023 689 1617
សារអេឡិចត្រូនិច jicaproject_gdt@yahoo.com



បោះពុម្ពផ្សាយដោយ អ្នកស្រី អ៊ិម៉ៃ តាកាកុ


សំរាប់អគ្គនាយកដ្ឋានពន្ធដារ និងប្រជាជនកម្ពុជា

ក្រុមគម្រោងរបស់ចៃការ (JICA) នឹងបោះពុម្ពផ្សាយកម្រងពត៌មានជារៀងរាល់ពីរខែម្តង និងចែកចាយទៅកាន់អ្នកអានទាំងអស់។ ប្រសិនបើអ្នកមានបំណងទទួលបានកម្រងពត៌មានតាមរយៈសារអេឡិចត្រូនិច សូមចុះឈ្មោះជាមួយយើងខ្ញុំតាមរយៈអាស័យដ្ឋាន៖
jicaproject_gdt@yahoo.com

ពត៌មានទាំងអស់ខាងលើនេះអាចទទួលបានតាមរយៈការស្នើសុំ។

# ពត៌មានសំខាន់ៗ

មានកម្មវិធីអាហារូបករណ៍ក្រោយថ្នាក់បរិញ្ញាប័ត្រជាច្រើនសំរាប់មន្ត្រីពន្ធដារទៅសិក្សានៅប្រទេសជប៉ុន។ ឥឡូវនេះ ពាក្យសុំអាហារូបករណ៍សំរាប់សាកលវិទ្យាល័យទាំងពីរខាងក្រោមនេះបានចាប់បើកហើយ។ <u>សូមទំនាក់ទំនងប្រធានផ្តល់ប្រឹក្សា និងនាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុនៅអគ្គនាយកដ្ឋានពន្ធដារមុនដំណាច់ខែមករា ឆ្នាំ២០១៣ សំរាប់ការធ្វើបទសម្ភាសន៍ និងលិខិតធានាអះអាង។</u>

1. Public Finance Program at National Graduate Institute for Policy Studies (GRIPS) Tokyo
   http://www.grips.ac.jp
2. Public Policy and Taxation at Yokohama National University (YNU) in Yokohama
   http://www.igss.ynu.ac.jp/wb-ppt/howtoapply01.html

អារូបករណ៍នេះ ស្ថិតក្រោមកិច្ចសហការរវាងប្រទេសជប៉ុន និងធនាគារពិភពលោក ហើយការបង្រៀននឹងត្រូវបានផ្តល់ដោយសាលាពន្ធដារជាតិប្រទេសជប៉ុន។ ពត៌មានអំពីវគ្គសិក្សាពន្ធដារនៃសាកលវិទ្យាល័យនានា ការហ្វឹកហ្វឺន សកម្មភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាលាពន្ធដារជាតិប្រទេសជប៉ុន ក្រោមគម្រោងរបស់ចៃការ (JICA) សូមស្វែងរកគេហទំព័រ៖
http://www.nta.go.jp/ntc/english/inter/index.htm